# ការពិតនៃថ្នាំបង្ការជំងឺ COVID-19៖ ការមានផ្ទៃពោះ និងការបំបៅកូនដោយទឹកដោះ

## មូលហេតុដែលអ្នកគួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19




- **ការទទួលចាក់ថ្នាំបង្ការគឺជាវិធីដ៏ល្អបំផុតសម្រាប់ការពារទារកដែលទើបនឹងកើតរបស់អ្នកពីបញ្ហាសុខភាពធ្ងន់ធ្ងរនានាដែលបណ្ដាលមកពីការឆ្លងជំងឺ COVID-19។** នៅពេលអ្នកបានចាក់ថ្នាំបង្ការរួចហើយ អ្នកបញ្ជូនសារធាតុទប់ទល់នឹងជំងឺ ឬអង់ទីក័រ (antibodies) ដែលការពារអ្នកពីជំងឺ ទៅដល់ទារកនៅក្នុងផ្ទៃរបស់អ្នកផងដែរ។ ទារករបស់អ្នកនឹងកើតមកដោយមានប្រព័ន្ធការពារពីជំងឺ COVID-19 ខ្លះ ផងដែរ។
- **ការទទួលចាក់ថ្នាំបង្ការកាត់បន្ថយហានិភ័យរបស់អ្នកពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ក្នុងអំឡុងពេលមានផ្ទៃពោះ។** អ្នកដែលមានផ្ទៃពោះហើយដែលមានផ្ទុកជំងឺ COVID-19 កាន់តែទំនងជានឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬត្រូវសម្រាលកូនមុនថ្ងៃទៀតផង។



**មានការណែនាំឱ្យទទួលចាក់ថ្នាំបង្ការក្នុងអំឡុងពេលមានផ្ទៃពោះ និងក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះ ពីអង្គការធំៗផ្នែកសុខភាពម្ដាយទាំងអស់។**

## ពេលដែលគួរចាក់ថ្នាំបង្ការ



- អ្នកអាចទទួលចាក់ថ្នាំបង្ការបាន រួមទាំងដូសជំរុញ នៅគ្រប់ដំណាក់កាលទាំងអស់នៃការមានផ្ទៃពោះ ឬនៅពេលដែលអ្នកកំពុងបំបៅកូនដោយទឹកដោះ ផងដែរ។
- **ការទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (បែបប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent) គឺជាការសំខាន់ណាស់** ប្រសិនបើការចាក់លំដាប់ដំបូង ឬដូសជំរុញចុងក្រោយបង្អស់របស់អ្នក រហូតមកដល់ពេលនេះមានរយៈពេលយ៉ាងហោចណាស់ 2 ខែហើយ។
- អ្នកក៏អាចចាក់ថ្នាំបង្ការផ្សេងទៀតក្នុងពេលតំណាលគ្នាផងដែរ រួមទាំងថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំ (flu) ហើយនិង Tdap (តេតាណូស ខាន់ស្លាក់ និងក្អកមាន់/tetanus, diptheira, and pertussis) ផងដែរ។

សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/covidvaccineschedules សម្រាប់ព័ត៌មានលម្អិត។

## មូលហេតុដែលថ្នាំបង្ការទាំងឡាយមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ



- ការសិក្សាផ្សេងៗ និងការពិនិត្យតាមដានលើផ្នែកសុវត្ថិភាពចំពោះមនុស្សជាច្រើនអ្នកដែលបានទទួលចាក់ថ្នាំបង្ការនៅពេលដែលពួកគេមានផ្ទៃពោះ បានបង្ហាញថាមិនមានការកើនឡើងនៃហានិភ័យពីបញ្ហាផ្នែកសុខភាពផ្ទៃពោះ ឬការប៉ះពាល់ដល់ទារក (បញ្ហាដែលអាចមានក្រោយសម្រាលហើយ/birth defects) ឡើយ។
- មិនមានថ្នាំបង្ការជំងឺ COVID-19 ណាមួយមានផ្ទុកមេរោគដែលមានជីវិតឡើយ។ ថ្នាំបង្ការទាំងឡាយមិនអាចធ្វើឱ្យអ្នក ឬទារករបស់អ្នកមានជំងឺ COVID ទេ។

ប្រសិនបើអ្នកមានសំណួរនានា សូមពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នក។ អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 1-866-626-6847 ឬផ្ញើសារជាអក្សរទៅកាន់លេខ 855.999.8525 ឬផ្ញើអ៊ីម៉ែលទៅកាន់ ContactUs@mothertobaby.org ឬក៏ចាប់ផ្ដើមការសន្ទនានៅលើគេហទំព័រ mothertobaby.org/ask-an-expert បានផងដែរ។

## ថ្នាំបង្ការគឺមិនគិតថ្លៃសម្រាប់មនុស្សគ្រប់រូប - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ

អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ។ មានទីតាំងចាក់ថ្នាំបង្ការជាច្រើនបើកបម្រើការជូននៅចុងសប្ដាហ៍ និងពេលល្ងាច ដែលមិនត្រូវការឱ្យមានការណាត់ជួបទេ។ ដើម្បីស្វែងរកទីតាំងមួយ៖

- ចូលទៅកាន់គេហទំព័រ **ph.lacounty.gov/howtogetvaccinated** ឬទូរស័ព្ទទៅលេខ **1-833-540-0473** មានផ្ដល់សេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 2-1-1 ឬសាកសួរគ្រូពេទ្យរបស់អ្នក ឬក៏អ្នកលក់ថ្នាំពេទ្យនៅក្នុងតំបន់ក៏បាន។
- មានការដឹកជញ្ជូនដោយមិនគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះ ផងដែរ។

**VaccinateLACounty.com**

County of Los Angeles Public Health

11-1-22 (Cambodian)